ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្ដីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ឯកឧត្តម Tsakhiagiin Elbegdorj ប្រធានាធិបតីនៃប្រទេសម៉ុងហ្គោលី **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញចូលរួម »**កិច្ចប្រជុំកំពូលអាស៊ី - អឺរ៉ុបលើកទី១១**« ដែលបានប្រព្រឹត្តទៅពីថ្ងៃទី **១៥ ដល់ទី ១៦ ខែកក្កដា ឆ្នាំ២០១៦** នៅទីក្រុងអ៊ូឡង់បាទ័រ ប្រទេសម៉ុងហ្គោលីក្រោម ប្រធានបទ »**២០ឆ្នាំនៃកិច្ចប្រជុំអាស៊ី - អឺរ៉ុបៈភាពជាដៃគូសម្រាប់អនាគតតាមរយៈការតភ្ជាប់**«។

កិច្ចប្រជុំកំពូលនេះបានទទួលការអញ្ជើញចូលរួមពីប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល ឬអ្នកតំណាងជាន់ខ្ពស់នៃបណ្ដាប្រទេសនៅអាស៊ី និងអឺរ៉ុបចំនួន៥១ប្រទេស ប្រធានសហភាពអឺរ៉ុប ប្រធានគណៈកម្មការអឺរ៉ុប និងអគ្គលេខាធិការអាស៊ាន ។ ដោយសង្កត់ធ្ងន់លើតួនាទីដ៏វិសេសនៃកិច្ចប្រជុំកំពូលអាស៊ី - អឺរ៉ុបដែលតំណាងឲ្យ៦០% នៃប្រជាជន និងផលិតផលក្នុងស្រុកសរុបរបស់ពិភពលោកថ្នាក់ដឹកនាំ ASEM បានគូសបញ្ជាក់ពីសារៈសំខាន់ក្នុងការពង្រឹងការតភ្ជាប់ផ្នែករឹង និងទន់រវាងអាស៊ី និងអឺរ៉ុបឲ្យធ្វើ ពាណិជ្ជកម្មបើកចំហ និងសមាហរណកម្មសេដ្ឋកិច្ចកាន់តែប្រសើរឡើង និងបង្កើនភាពជាដៃគូជិតស្និទ្ធនៃតំបន់ទាំងពីរ ដើម្បីដោះស្រាយបញ្ហាប្រឈម រួមមានជាអាទិ៍ ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ទេសន្តរប្រវេសន៍ ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងអំពើជ្រុលនិយមហិង្សាជាដើម។

ខណៈពេលថ្លែងសុន្ទរកថានៅក្នុងសម័យប្រជុំពេញអង្គ **សម្ដេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានបង្ហាញទស្សនៈផ្ទាល់ខ្លួនថា ដោយយកចិត្តទុកដាក់ពិចារណាទៅលើបញ្ហាសកលនាពេលបច្ចុប្បន្ននេះ ASEM គួរបន្ត (១) កំណត់ថាមភាពថ្មីសម្រាប់ពង្រឹងទំនាក់ទំនងអាស៊ី - អឺរ៉ុប ដើម្បីទាញយកឱកាសអភិវឌ្ឍន៍នានាចេញពីការតភ្ជាប់រូបវន្ត ការតភ្ជាប់ស្ថាប័នព្រមទាំងទំនាក់ទំនងប្រជាជន និងប្រជាជន (២) ផ្ដល់ការគាំទ្រជានិច្ចដល់ការអនុវត្តន៍សមាហរណកម្មតំបន់ និងអនុតំបន់ និងយន្តការតភ្ជាប់នានា រួមមានដូចជា មូលនិធិផ្លូវសូត្រ មូលនិធិ

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

កិច្ចសហប្រតិបត្តិការតាមសមុទ្រចិន-អាស៊ាន ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី និងយន្តការពហុភាគីដែលមានស្រាប់ផ្សេងៗទៀត ដើម្បីចូលរួមចំណែកពង្រឹងការតភ្ជាប់ក្នុងតំបន់ និង (៣) ពង្រឹងប្រព័ន្ធសន្តិសុខដែលអាចការពារប្រជាជន និងប្រទេសពីហានិភ័យនានាកើតចេញពីការតភ្ជាប់កាន់តែទូលំទូលាយ មានជាអាទិ៍ ៖ សន្តិសុខជាតិ ការជួញដូរគ្រឿងញៀន អំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនដែលកើតចេញពីកំណើននៃលំហូរប្រជាជន និងទំនិញ ។

កិច្ចប្រជុំកំពូលរយៈពេលពីរថ្ងៃនេះ បានបញ្ចប់ទៅជាមួយនឹងការអនុម័តឯកសារលទ្ធផលសំខាន់បីគឺ៖

(១) "**សេចក្តីប្រកាសអ៊ូឡង់បាទ័រស្តីពីការឈានចូលទសវត្សរ៍ទីបីនៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប**" ដែលទទួលស្គាល់ពីការចូលរួមចំណែករបស់កិច្ចប្រជុំអាស៊ី-អឺរ៉ុប ក្នុងការពង្រីកកិច្ចសន្ទនានយោបាយ ពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច បង្កើនការផ្លាស់ប្តូរសង្គមវប្បធម៌ និងដោះស្រាយបញ្ហាប្រឈមនានាដែលតំបន់ទាំងពីរជួបប្រទះ។ សេចក្តីប្រកាសនេះ ក៏បានគូសបញ្ជាក់ផងដែរពីការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំ ក្នុងការដឹកនាំកិច្ចប្រជុំមួយនេះឈានទៅរកជោគជ័យក្នុងទសវត្សរ៍ទីបីរបស់ខ្លួន តាមរយៈការពង្រឹងភាពជាដៃគូ ការយកចិត្តទុកដាក់លើកិច្ចសហប្រតិបត្តិការដែលទទួលបានអត្ថប្រយោជន៍ជាក់ស្តែង ការជម្រុញការតភ្ជាប់លើគ្រប់វិស័យទាំងអស់ និងការលើកកម្ពស់ភាពក្រៅផ្លូវការ ការចងក្រងបណ្តាញ និងភាពបត់បែនទន់ភ្លន់។

(២)" **សេចក្តីថ្លែងការណ៍របស់ប្រធានអង្គប្រជុំ**" ដែលបានវាយតម្លៃពីវឌ្ឍនភាព និងបញ្ហាប្រឈមនានារបស់ ASEM ក្នុងរយៈពេល២០ឆ្នាំ ។ សេចក្តីថ្លែងការណ៍នេះ បានកំណត់គោលដៅរួមសម្រាប់អនាគត គូសបញ្ជាក់ពីសារៈសំខាន់នៃការពង្រឹងការតភ្ជាប់លើគ្រប់វិស័យទាំងអស់ លើកកម្ពស់កិច្ចសហប្រតិបត្តិការលើបញ្ហានយោបាយនិងសន្តិសុខ ព្រមទាំងសង្កត់ធ្ងន់លើតម្រូវការឲ្យមានការពិចារណាឡើងវិញលើវិធីសាស្ត្រអនុវត្តការងាររបស់ ASEM ។

(៣)" **សេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំ ASEM ស្តីពីភេរវកម្មអន្តរជាតិ**" បានថ្កោលទោសយ៉ាងដាច់អហង្ការចំពោះការវាយប្រហារភេរវកម្មដ៏សាហាវយង់ឃ្នង នៅក្នុងតំបន់អឺរ៉ុប អាស៊ី និងតំបន់ផ្សេងទៀត ដែលក្នុងនោះរួមមានទាំងការវាយប្រហារនៅទីក្រុងនីស(Nice) ប្រទេសបារាំងផងដែរ ព្រមទាំងបានគូសបញ្ជាក់ជាថ្មីពីការថ្កោលទោសច្បាស់លាស់ដ៏ខ្លាំងក្លាចំពោះគ្រប់រូបភាព និងសកម្មភាពទាំងអស់នៃអំពើភេរវកម្ម ទោះបីជាអំពើទាំងនោះប្រព្រឹត្តដោយអ្នកណា នៅកន្លែងណា និងក្នុងគោលបំណងអ្វីក៏ដោយ។

ក្រៅពីកិច្ចប្រជុំកំពូល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាទ្វេភាគីជាមួយ៖

(១) **ឯកឧត្តម លី គឺឈាំង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន ។ ភាគីទាំងពីរបានពិភាក្សាអំពីការផ្តល់ជំនួយអភិវឌ្ឍន៍ដល់ប្រទេសកម្ពុជាលើដំណើរការរៀបចំការបោះឆ្នោត សុខភាពអប់រំ និងការទទួលបានទឹកស្អាតដែលក្នុងនោះភាគីចិនបានសន្យាផ្តល់ជំនួយឥតសំណងចំនួន **៣៦០០ លានយ៉េន** (ប្រហែល **៦០០លានដុល្លារ**) ក្នុងរយៈពេលបីឆ្នាំ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ ២០១៩។

(២) **ឯកឧត្តម ស៊ិនហ្សូ អាបេ** នាយករដ្ឋមន្ត្រីនៃប្រទេសជប៉ុន ។ ការពិភាក្សាទ្វេភាគីនេះ បានផ្តោតជាសំខាន់លើការជម្រុញពាណិជ្ជកម្មនិងវិនិយោគ និងទេសចរណ៍រវាងប្រទេសទាំងពីរ ព្រមទាំងកិច្ចសហប្រតិបត្តិការរក្សាសន្តិភាព ។ តាមការគ្រោងទុក ការហោះហើរផ្ទាល់រវាងកម្ពុជា និងជប៉ុន នឹងចាប់ផ្តើមដំណើរការនៅក្នុងខែកញ្ញា ឆ្នាំ២០១៦ ។

(៣) **លោកជំទាវ ផាក គឿនហេ** ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ។ ភាគីទាំងពីរ បានផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកលើបញ្ហាទ្វេភាគី និងតំបន់ ។

ភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៦